ISSN 1810-6358

## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

## Cambodia Development Resource Institute

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កញ្ញា ២០០៦ / September 2006

ផាន់ ដាលីស / **Phann Dalis**
ប៊ុន ដូរីណា / **Pon Dorina**
ហ៊ីង វុត្ថា / **Hing Vutha**
ភឹម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ និង យេន សុផានី

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**
*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី២ គំរោងវិនិយោគអនុម័តសរុបគិតជាទ្រព្យសកម្មជាប់លាប់មាន ២១០០,៩លានដុល្លារ ក្នុងនេះ វិស័យឧស្សាហកម្មមាន ១០,០លានដុល្លារ (៣០,៦%ខាងកាត់ដេរ) រឺ ធ្លាក់ចុះ ៦៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៥ (២៩,៥លានដុល្លារ) ។ គំរោងអនុម័តក្នុងវិស័យកសិកម្មមាន ៥៨,៩លានដុល្លារ ឯនៅត្រីមាសដូចគ្នា ឆ្នាំ២០០៥ គ្មានគំរោងអនុម័តក្នុងវិស័យនេះទេ ។ គំរោងអនុម័តក្នុងវិស័យសេវាកម្មកើនពី ៣០,០លានដុល្លារនៅឆ្នាំ២០០៥ ដល់ ២០៣២,០លានដុល្លារ ដោយសារគំរោងសាងសង ។

In the second quarter, the total value of fixed asset approvals amounted to USD2100.9 m. Approvals in the industrial sector were USD10.0 m, of which 30.6 percent was in garments. Compared to the same period of 2005, industrial approvals declined by 66 percent, from USD29.5 m. Agricultural sector approvals accounted for USD58.9 m, while there were no approvals in this sector in the same quarter of 2005. Service sector approvals increased from USD30.0 m in 2005 (April-May) to USD2032.0 m in this quarter, due to construction approvals.

**Private Investments in Service Sector Approved by CDC: 2003 Q4–2006 Q2***




*Including expansion projects.*
** Up to May.*
Source: Council for the Development of Cambodia

នៅត្រីមាសទី២ ភ្ញៀវបរទេសមកកម្ពុជាក្នុងគោលបំណងលំហែកំសាន្ត មាន ២៩២.៦៨២នាក់ រឺស្មើនឹង ៦៧% នៃចំនួនភ្ញៀវសរុប (៤៣៥.៨៨៩នាក់) ។ ភ្ញៀវទេសចរថយចុះអស់ ២៧% ពីកំរិត ៤០០.៤១៧នាក់នៅត្រីមាសមុន ។ ប៉ុន្តែធៀបនឹងពេលដូចគ្នា ឆ្នាំមុន ភ្ញៀវមកលំហែកំសាន្ត កើនបាន ២១% ។

The number of foreign arrivals in Cambodia for holiday purposes in the second quarter was 292,682; this was 67 percent of total arrivals (435,889 persons). Tourists decreased by 27 percent from 400,417 persons in the previous quarter. Compared to the same quarter last year, however, visitors for holidays increased by 21 percent.

**Foreign Visitor Arrivals 2003 Q4–2006 Q2**




Source: Ministry of Tourism

នៅត្រីមាសទី២ ការអនុមតិគំរោងសាងសង់នៅភ្នំពេញមានតំលៃ ៨២,២៧ លានដុល្លារ រឺកើន ២២% ធៀបនឹងត្រីមាសមុន ។ ក្នុងនេះ សំណង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះអស់ ៤៣% មកត្រឹម ៥,៧លានដុល្លារ រីឯ សំណង់ផ្ទះល្វែង និងសំណង់ផ្សេងទៀត កើន ៣០% ដល់ ៥១,៨លានដុល្លារ និងកើន ៤២% ដល់ ២៤,៧លានដុល្លារ ។ តំលៃសាងសង់សរុប ធ្លាក់ចុះអស់ ២១% ធៀបនឹងត្រីមាសទី២ ឆ្នាំមុន ។

Construction project approvals in Phnom Penh, valued at USD82.27 m in the second quarter, increased by 22 percent from the preceding quarter. Of this, villa and house construction shrank by 43 percent to USD5.7 m, while flat and other construction activities rose by 30 percent to USD51.8 m and by 42 percent to USD24.7 m, respectively. The total value of construction decreased by 21 percent compared to the second quarter of last year.

**Construction Project Approvals: Phnom Penh 2003 Q4–2006 Q2**




Source: Phnom Penh Municipality

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

ថ្លៃប្រេងសាំងជាមធ្យមនៅភ្នំពេញ បន្តកើនឡើងដល់ ៤១៨៣រៀល/លីត្រ នៅខែសីហា រឺ កើន ១,១% ពីកំរិត ៤១៣៧រៀល/លីត្រ នៅខែមុន ។ នៅពេលជាមួយគ្នា ថ្លៃម៉ាស៊ូតឡើងដល់ ៣៣៧៥រៀល/លីត្រ រឺ ២,0% ខ្ពស់ជាងនៅខែកក្កដា (៣៣១0រៀល/លីត្រ) ។

The average selling price of gasoline in Phnom Penh continued to increase, to 4183 riels/litre in August, a rise of 1.1 percent from 4137 riels/litre in the preceding month. At the same time, the price of diesel oil was 3375 riels/litre, 2.0 percent more than the 3310 riels level in July.

**Gasoline and Diesel Prices: Phnom Penh June 2005–August 2006**




Sources: CDRI and National Institute of Statistics

នៅខែកក្កដា ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ កើន ១,៦% ធៀបនឹងខែមិថុនា ។ រឿងនេះបណ្តាលមកពីកំណើនថ្លៃម្ហូបអាហារ ២,៤% និងការដឹកជញ្ជូននិងទូរគមនាគមន៍ ២,១% ។ ធៀបនឹងខែកក្កដា ឆ្នាំមុន ថ្លៃទំនិញប្រើប្រាស់ទូទៅ កើន ៥,១% ថ្លៃម្ហូបអាហារ កើន ៦,៣% និងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ១១,២% ។

In July, consumer prices in Phnom Penh rose by 1.6 percent from June. This was due to an increase of food prices of 2.4 percent and transportation and communication of 2.1 percent. Compared to July last year, overall prices rose by 5.1 percent, food by 6.3 percent and transportation and communication by 11.2 percent.

**Consumer Price Index**
(July–December 2000=100)




Source: National Institute of Statistics

យោងតាមអង្កេត វបសអ នៅខែមិថុនា លើកម្មករងាយរងគ្រោះ ប្រាក់ចំនូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ កើនបាន ៨,៥% ធៀបនឹងខែមុន ដល់ ៨៥៤៦រៀល/ថ្ងៃ និងរបស់កម្មករសំណង់គ្មានជំនាញ កើនបាន ៧,២% ដល់ ៦៤0៧រៀល/ថ្ងៃ ។ ចំណូលប្រចាំរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ១,១% មកត្រឹម ៨៧៩0រៀល/ថ្ងៃ ។ ធៀបនឹងខែឧសភា ២00៥ ចំណូលរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ២៣% រីឯ ចំណូលរបស់កម្មករសំណង់គ្មានជំនាញធ្លាក់ចុះ ២១% ប៉ុន្តែចំណូលរបស់អ្នកធាក់ស៊ីក្លូ កើនបាន ១0,៦% ។

According to CDRI’s survey of vulnerable workers in May, real daily earnings of cyclo drivers increased by 8.5 percent from the previous month, to 8546 riels/day and of unskilled construction workers by 7.2 percent to 6407 riels. Daily earnings of motorcycle-taxi drivers decreased by 1.1 percent to 8790 riels. The earnings of motorcycle-taxi drivers declined by 23 per cent and of unskilled construction workers by 21 percent from May 2005, while cyclo drivers rose by 10.6 percent.

**Vulnerable Workers: Phnom Penh Real Daily Average Earnings November 2003-May 2006**




Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ
# Exchange Rates and Monetary Developments

នៅខែសីហា ប្រាក់រៀល ធ្លាក់ថ្លៃទល់នឹងដុល្លារUS អស់ 0,៤% មកត្រឹម ៤១៣៩រៀល/ដុល្លារUS ធៀបនឹងការធ្លាក់ចុះ 0,១% នៅខែមុន ។ បើធៀបនឹងខែសីហា ២00៥ ប្រាក់រៀលបានឡើងថ្លៃ ១,0% ទល់នឹងដុល្លារUS ។

The riel depreciated against the US dollar by 0.4 percent in August, to 4139 riels/dollar, compared with a 0.1 percent decline in the previous month. Compared to August 2005, the riel has appreciated 1.0 percent against the dollar.

**Riels per US Dollar**
**June 2005–August 2006**




Sources: National Bank of Cambodia and CDRI

នៅខែសីហា ប្រាក់រៀលប្តូរបាន ១១0រៀល/បាត រឺ ធ្លាក់ថ្លៃអស់ 0,៩% ធៀបនឹងកំរិត ១0៩រៀល/បាត នៅខែមុន ។ តំលៃប្រាក់រៀលគ្មានប្រែប្រួលទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបាន ២៥រៀល/១00ដុង ប៉ុន្តែឡើងថ្លៃ ៥,0% ធៀបនឹង ខែសីហា ២00៥ (២៦,៣រៀល/១00ដុង) ។

In August, 110 riels bought one baht, a depreciation of the riel of 0.9 percent from 109 riels/baht in the preceding month. The riel's value was unchanged against the Vietnamese dong, at 25 riel per 100 dong, a 5.0 percent appreciation from 26.3 riel per 100 dong in August 2005.

**Riels against THB and VND**
**June 2005–August 2006**




Source: CDRI

នៅខែមិថុនា រូបិយវត្ថុទូទៅ M2 កើនតាមអត្រាប្រចាំឆ្នាំ ១៨% ហើយការផ្គត់ផ្គង់រូបិយវត្ថុ M1 កើនតាមអត្រាប្រចាំឆ្នាំ ២៨% ។ ក្នុងរយៈ ១២ខែ មកដល់ខែមិថុនា ២00៦ រូបិយវត្ថុទូទៅ កើន ៣១% ធៀបនឹងកំណើន ២៨% សំរាប់ខែឧសភា ២00៦ ។

In June, liquidity (M2) grew at an annualised growth rate of 18 percent, and money supply (M1) grew at an annualised growth rate of 28 percent. Over the previous 12 months, liquidity grew by 31 percent, compared to a growth rate of 28 percent in the year to May 2006.

**Monetary Survey**
**August 2005–June 2006**




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅត្រីមាសទី២ ការនាំចេញសរុបរបស់កម្ពុជាមាន ៦៥២,៥លានដុល្លារ រឺកើន ៨,២% ធៀបនឹងត្រីមាសទី១ ។ ការនាំចេញសំលៀកបំពាក់កើន ១១,២% ដល់ ៦៣២,៤លានដុល្លារ ហើយការនាំចេញកៅស៊ូកើន ២៥,៦% ដល់ ៩,៨លានដុល្លារ ។ ការនាំចេញត្រីធ្លាក់ចុះ ៤៧% មកត្រឹម ១,0លានដុល្លារ ហើយការនាំចេញអង្ករធ្លាក់ចុះ ៨៧% មកត្រឹម 0,២លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២00៥ ការនាំចេញសំលៀកបំពាក់ធ្លាក់ចុះអស់ ២៧% ។

Cambodia’s total exports in the second quarter amounted to USD652.5 m, 8.2 percent more than in the first quarter. Garment exports grew by 11.2 percent to USD632.4 m, and rubber exports rose by 25.6 percent to USD9.8 m. Exports of fish decreased by 47 percent to USD1.0 m and of rice by 87 percent to USD0.2 m. However, garment exports declined by 27 percent compared to the same quarter of 2005.

**Cambodia: Main Exports**
**2003 Q4–2006 Q2**




Source: Customs and Excise Department

នៅត្រីមាសទី២ ការនាំចូលបារី កើនដល់ ១១៣,៤ពាន់លានរៀល ធៀបនឹង ១១២,៦ពាន់លានរៀល នៅត្រីមាសទី១ ។ ការនាំចូលស៊ីម៉ង់ត៍ កើនបាន ៥,0% ដល់ ៥៨,៤ពាន់លានរៀល ប៉ុន្តែ ការនាំចូលដែកបែរជាធ្លាក់ចុះអស់ ៥,៦% មកត្រឹម ៣៣,៥ពាន់លានរៀល ។

In the second quarter, imported cigarettes rose to KHR113.4 bn, up from KHR112.6 bn in the first quarter. Imports of cement increased by 5.0 percent to KHR58.4 bn, while steel imports fell by 5.6 percent to KHR33.5 bn.

**Imports of Cigarettes and Construction Materials**
**2003 Q4–2006 Q2**




Source: Customs and Excise Department

នៅត្រីមាសទី២ ការនាំចូលម៉ាស៊ូត មានចំនួន ១១.៨00តោន ឯការនាំចូលសាំង មាន ៣៤.៨00តោន ។ ការនាំចូលម៉ាស៊ូតកើន ៥១% ធៀបនឹងត្រីមាសមុន ឯ ការនាំចូលសាំង កើន 0,៩% ។ ការនាំចូលទាំងសាំង និងម៉ាស៊ូត កើនខ្ពស់ជាងនៅត្រីមាសដូចគ្នា ឆ្នាំមុន ដល់ទៅ ៥,៥% និង ៥៣% ។

Diesel oil imports amounted to 11,800 tonnes and gasoline imports to 34,800 tonnes in the second quarter. Diesel imports increased by 51 percent from the preceding quarter, while gasoline imports increased by 0.9 percent. Imports of both gasoline and diesel were higher than in the same quarter last year, by 5.5 percent and 53 percent, respectively.

**Petroleum Product Imports**
**2003 Q4–2006 Q2**




Source: Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

នៅឆ្នាំ២០០៥ ធនធានសរុបសំរាប់កម្មវិធីសិលា មានចំនួន ៣៩,៣១លាន ដុល្លារ ក្នុងនេះ មូលនិធិរដ្ឋាភិបាលមាន ៣៥% ភាពជាដៃគូសំរាប់អភិបាលកិច្ច មូលដ្ឋាន (PLG) មាន ៣១% ឯ ៣៤% ទៀត បានមកពីប្រភពផ្សេងៗ ដូចជា IFAD និង UNICEF ។ ប្រភពមូលនិធិ PLG សំខាន់ៗគឺ DFID, SIDA និង UNDP ។ អ្នកផ្តល់ជំនួយទាំងនេះផ្តល់ការគាំទ្រស្នូល ដល់កម្មវិធីសិលា ដែលជាកម្មវិធីពង្រឹងអភិបាលកិច្ច ការគ្រប់គ្រង និង ការកសាងសមត្ថភាព ។

In 2005, total resources available for the SEILA programme amounted to USD39.31 m, of which government funds accounted for 35 percent, Partnership for Local Governance 31 percent and 34 percent from other sources, including IFAD and UNICEF. The main PLG fund sources were USD7.5 m from United Kingdom/DFID, Sweden/SIDA, USD5.0 m and UNDP, USD0.4 m. These PLG donors represent the core support of SEILA, which was used to develop governance, management and capacity building.

**SEILA 2005 PLG Resources, by Major Donors**




Source: Seila Task Force, Annual Work Plan and Budget 2005

ក្នុងគំរោងថវិកាសរុបឆ្នាំ២០០៥របស់សិលា មូលនិធិ PLG មាន ១២,២៤ លានដុល្លារ ក្នុងនេះ ៤២% បានបែងចែកឱ្យវិនិយោគថ្នាក់ខេត្ត និងថ្នាក់ជាតិ, ៣៣% សំរាប់ការគាំទ្រដល់កម្មវិធីថ្នាក់ខេត្ត និងថ្នាក់ជាតិ, និង ២៥% សំរាប់ សហប្រតិបត្តិការបច្ចេកទេស ។ មូលនិធិ LPG ជួយដល់ការអភិវឌ្ឍន៍ ឃុំ/សង្កាត់ និងការផ្តល់សេវាគាំទ្រដល់គ្រប់ក្រសួង ។

Of the total SEILA 2005 budget, PLG amounted to USD12.24 m. Forty-two percent (USD5.14 m) of the PLG budget is allocated to national and provincial investment, 33 percent (USD4.04 m) for provincial and national programme support and 25 percent (USD3.06 m) for technical cooperation. These PLG funds assist commune/sangkat development and also support services to all ministries. This is achieved by funding activities related to the government reforms by providing advisers and consultants to both the provincial and national levels of government.

**SEILA 2005 PLG Allocation**




Source: Seila Task Force, Annual Work Plan and Budget 2005

រាជធានីភ្នំពេញមានគំរោងអភិវឌ្ឍន៍សង្កាត់ ១០៦គំរោង ដែលមានការផ្តល់ មូលនិធិ ៣,១ពាន់លានរៀលពីកម្មវិធីសិលា នៅឆ្នាំ២០០៥ រឺ ២៤% ច្រើនជាង ឆ្នាំ២០០៤ ។ នៅក្នុងថវិកាសរុប សំណង់ផ្លូវចាក់កៅស៊ូ បានទទួល ០,៤ពាន់ លានរៀល ផ្លូវបេតុង ១,០១ពាន់លានរៀល និងផ្លូវក្រាលឡាតេរីត ០,៥៦ពាន់ លានរៀល ។ ប្រព័ន្ធរំដោះទឹក ប្រឡាយនិងលូកាត់ថ្នល់ និង ផ្លូវលំ បានទទួល ១,០៥ពាន់លានរៀល ០,០៧ពាន់លានរៀល និង ០,០២ពាន់លានរៀល ។

Phnom Penh had 106 sangkat development projects which were allocated KHR3.1 bn by SEILA in 2005, 24 percent more than in 2004. Of the total budget, macadam road construction received KHR0.4 bn for 11 projects, concrete roads and laterite roads with culverts received KHR 1.01 bn (29 projects) and KHR 0.56 bn (21 projects), respectively. Drainage installation, canals and double culverts with gates and earth roads received KHR 1.05 bn (40 projects), KHR 0.07 bn (4 projects) and KHR 0.02 bn (1 project), respectively.

**SEILA 2005 Sangkat Development Projects, Phnom Penh**




Source: Seila Task Force, Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែមេសា ដំណើរការថវិកាចរន្តរបស់រដ្ឋាភិបាល មានអតិរេក ៦២,០ ពាន់លានរៀល ធៀបនឹងអតិរេក ៣២,០ពាន់លានរៀល នៅខែមីនា ។ កំណើននេះ បណ្តាលមកពីការធ្លាក់ចុះចំណាយចរន្ត ហើយ ចំណូលចរន្ត ក៏ធ្លាក់ចុះតែបន្តិចបន្តួច នៅពេលជាមួយគ្នា ។

Government current budget operations showed a surplus of KHR62.0 bn in April, compared to KHR32.0 bn in March. This increase derived from a fall in current expenditure, while current revenue slightly decreased at the same time.

**Current Budget Operations**
**February 2005–April 2006**




*Note: Provisional for2006.*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមេសា ចំណូលចរន្តរបស់រដ្ឋាភិបាលមានសរុប ២០៥,៣ពាន់លានរៀល រឺ ៣,០% តិចជាងនៅខែមុន និង១,១ ទាបជាងនៅខែដូចគ្នា ឆ្នាំមុន ។ ធៀបនឹង ខែមីនា ចំណូលពន្ធក្នុងស្រុក និងចំណូលមិនមែនពន្ធ កើន ០,៧% ដល់ ៥៦,៣ ពាន់លានរៀល និង ៨,៦% ដល់ ៣៩,១ពាន់លានរៀល រីឯចំណូលពន្ធនាំចេញ នាំចូលធ្លាក់ចុះ ៨,១% មកត្រឹម ១០៩,៩ពាន់លានរៀល ។ ប៉ុន្តែ ធៀបនឹង ខែមេសា ២០០៥ ការប្រមូលពន្ធនាំចេញនិងនាំចូល កើន ២,១% រីឯ ចំណូលពន្ធក្នុងស្រុក និងចំណូលមិនមែនពន្ធ ធ្លាក់ចុះ ២,១% និង ៨,០% ។

Government current revenue totalled KHR205.3 bn in April, 3.0 percent less than in the preceding month and 1.1 percent lower than in the same month last year. Compared to March, domestic tax and non-tax revenues increased by 0.7 percent to KHR56.3 bn and by 8.6 percent to KHR39.1 bn, while import and export tax revenue decreased by 8.1 percent to KHR109.9 bn. However, import and export tax collection was 2.1 percent more than in April 2005, while domestic tax and non-tax revenues fell by 2.1 percent and 8.0 percent.

**Current Revenue**
**February 2005–April 2006**




*Note: Provisional for 2006.*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមេសា ចំនាយថវិកាចរន្តសរុប មាន ១៤៣,៦ពាន់លានរៀល រឺធ្លាក់ចុះ ២០% ធៀបនឹងខែមីនា ប៉ុន្តែវាកើន ៧៧% ធៀបនឹងខែមេសា ២០០៥ ។ ធៀបនឹងខែមុន ចំណាយលើសន្តិសុខ និងការពារជាតិ ធ្លាក់ចុះ ៤១% មកត្រឹម ២៦,២ពាន់លានរៀល, ចំនាយលើរដ្ឋបាលសង្គមកិច្ច ថយចុះ ១៣% មកត្រឹម ៦១,៣ពាន់លាន, លើរដ្ឋបាលទូទៅ ថយចុះ ៥,៥% មកត្រឹម ៣១,១ពាន់លាន រីឯចំនាយលើរដ្ឋបាលសេដ្ឋកិច្ចកើន ២,៩% ដល់ ១៤,១៧ពាន់លានរៀល ។

In April, government current spending totalled KHR143.6 bn, a 20 percent reduction from March, but a 77 percent increase from April 2005. Compared with the previous month, expenditures on defence and security dropped by 41 percent to KHR26.2 bn, on social administration by 13 percent to KHR61.3 bn, on general administration by 5.5 percent to KHR31.1 bn and on other government services by 41 percent to KHR10.8 bn. Expenditures on economic administration rose by 2.9 percent to KHR 14.17 bn in April.

**Current Expenditure**
**February 2005–April 2006**




*Note: Provisional for 2006.*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមិថុនា ការនាំចេញទំនិញរបស់ US និងជប៉ុន កើនឡើង រីឯការនាំចេញរបស់តំបន់អឺរ៉ូធ្លាក់ចុះ។ ការនាំចេញរបស់US កើនពី ៨៤,២១ ពាន់លានដុល្លារនៅខែឧសភា ទៅដល់ ៨៦,៥៧ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ ធ្លាក់ចុះបន្តិចអស់ ០,៣% ធៀបនឹងខែមុនមកត្រឹម ១៤៤,៧៤ពាន់លានដុល្លារ ។ ការនាំចេញរបស់ជប៉ុនកើនបាន ១០% ធៀបនឹងខែមុន ដល់ ៥៥,៦៤ពាន់លានដុល្លារ។

In June, goods exports of the US and Japan increased, while goods exports of the Euro zone decreased. US exports rose from USD84.21 bn in May to USD86.57 bn. Euro zone goods exports decreased by 0.3 percent from the previous month to USD144.74 bn. Japan's goods exports increased by 10 percent from the previous month to USD55.64 bn.

**Goods Exports: US, Euro zone and Japan**
(USD bn)




Sources: BEA, Eurostat and OECD

នៅខែមិថុនា ការនាំចេញទំនិញរបស់កូរ៉េខាងត្បូង កើន ០,១% ធៀបនឹងខែមុន ដល់ ២៧,៩៦ពាន់លានដុល្លារ និងកើន ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ការនាំចេញទំនិញរបស់តៃវ៉ាន់ ធ្លាក់ចុះ ៤,៣% ធៀបនឹងខែមុនមកត្រឹម ១៨,១០ពាន់លានដុល្លារ ប៉ុន្តែកើន ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

In June, goods exports of South Korea increased by 0.1 percent from the previous month to USD27.96 bn and by 28 percent from the same period last year. Taiwan's goods exports decreased by 4.3 percent from the previous month to USD18.10 bn, but increased by 22 percent from the same month last year.

**Goods Exports: South Korea and Taiwan**
(USD bn)




Sources: National statistics departments of each country

នៅខែមិថុនា ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ២,២៦ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,១២ពាន់លានដុល្លារនៅខែឧសភា ។ ការនាំចេញសរុបកើន ២,៧% ដល់ ១៣,០៥ពាន់លានដុល្លារ រីឯ ការនាំចូលសរុបកើន ១,៩% ដល់ ១០,៧៩ពាន់លានដុល្លារ ។ ដោយឡែកផលិតផលអគ្គិសនី និងអេឡិចត្រូនិក មានចំណែក ៤៩% (៦,៤៤ពាន់លានដុល្លារ) នៅក្នុងការនាំចេញសរុប ។

In June, Malaysia recorded a trade surplus of USD2.26 bn, compared to USD2.12 bn in May. Total exports rose by 2.7 percent to USD13.05 bn, while total imports increased by 1.9 percent to USD10.79 bn. Electrical and electronic products accounted for 49 percent of total exports (USD6.44 bn).

**Malaysia: External Trade**
(USDbn)




Source: Department of Statistics Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅជប៉ុន កើន ១,០% នៅរយៈមួយឆ្នាំដល់ខែមិថុនា ។ បើតាមសារព័ត៌មាន Nihonkeizai Shimbun កំណើននេះបណ្តាលមកពីការឡើងថ្លៃថាមពល និងថ្លៃសេវាកម្ម ។ ក្នុងកំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់ កើន ៤,៣% នៅ US និង ២,១% នៅតំបន់អឺរ៉ូ ។

Japan's consumer prices rose by 1.0 percent in the year to June. According to *Nihonkeizai Shimbun* this increase stemmed from the higher cost of energy as well as higher charges for services. During the same period, consumer prices rose by 4.3 percent in the US and by 2.1 percent in the Euro zone.

**Inflation Rate: US, Euro zone & Japan**

(prices change from a year earlier)




*Note: The latest data available are for June 2006.*

Sources: IMF and *Economist* (29 July 2006)

ថ្លៃទំនិញប្រើប្រាស់ទូទៅនៅហុងកុងនៅខែមិថុនា កើន ២,២% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ធៀបនឹងកំណើន ២,១% នៅខែឧសភា ។ រឿងនេះបណ្តាលមកពីកំណើនថ្លៃបន្លែស្រស់ និងថ្លៃសេវាប្រើប្រាស់តាមគ្រួសារ ។ នៅកំឡុងពេលដូចគ្នា អតិផរណាទំនិញប្រើប្រាស់ នៅចិន និងកូរ៉េខាងត្បូង មានកំរិត ១,៥% និង ២,៦% ។

Hong Kong's overall consumer prices in June were 2.2 percent higher than a year earlier, compared to 2.1 percent higher in May. This was attributable to increases in the prices of fresh vegetables and charges for household services. During the same period, consumer inflation in China and South Korea was 1.5 percent and 2.6 percent respectively.

**Inflation Rate: China, Hong Kong & South Korea**

(prices change from a year earlier)




*Note: The latest data available are for June 2006.*

Sources: IMF and *Economist* (July 29th 2006)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់របស់សិង្ហបុរី នៅខែមិថុនា កើន ១,៤% ខ្ពស់ជាងខែដូចគ្នា ឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះឆ្លុះបញ្ចាំងពីកំណើនថ្លៃម្ហូបអាហារ សំលៀកបំពាក់ ស្បែកជើង ផ្ទះសំបែង ការអប់រំ សំភារៈការិយាល័យ និងការថែទាំសុខភាព ។ អត្រាអតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ មានកំរិត ៣,៩% នៅម៉ាឡេស៊ី និង ៥,៩% នៅថៃ ។

Singapore's consumer price index in June was 1.4 percent higher than in the same month a year ago. According to the Department of Statistics of Singapore, this reflected higher costs for food, clothing and footwear, housing, education, stationery and health care. The year-on-year inflation rate was 3.9 percent in Malaysia and 5.9 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(prices change from a year earlier)




*Note: The latest data available are for June 2006.*

Sources: IMF and *Economist* (July 29th 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែសីហា ដុល្លារUS មានការឡើងចុះចំរុះទល់នឹងរូបិយវត្ថុចំបងៗ ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១៥,៨យ៉េន/ដុល្លារUS រឺ ធ្លាក់ថ្លៃបន្តិច ធៀបនឹងខែកក្កដា ។ ទល់នឹងអឺរ៉ូ វាប្តូរបាន ០,៧៩អឺរ៉ូ/ដុល្លារUS រឺ ឡើងថ្លៃ ១,០% ធៀបនឹងខែមុន ។

In August, the movement of the US dollar was mixed against other major currencies. Against the Japanese yen, the rate was 115.8 JYP/USD, a marginal depreciation from July. The dollar bought EUR0.79, a 1.0 percent appreciation from the preceding month.

**EUR & JPY against USD**

August 05–August 06 (Monthly Average)




Source: Federal Reserve Bank of New York

នៅខែសីហា ២០០៦ ប្រាក់វ៉ុនកូរ៉េខាងត្បូង ប្តូរបាន ៩៦០,៩៥វ៉ុន/ដុល្លារUS រឺធ្លាក់ថ្លៃបន្តិចទល់នឹងដុល្លារUS បើធៀបនឹងមួយខែមុនដែលប្តូរបាន ៩៥៤,៤៥វ៉ុន/ដុល្លារUS ។ នៅកំឡុងពេលដូចគ្នា ដុល្លារហុងកុង សឹងគ្មានការប្រែប្រួលទល់នឹង ដុល្លារUS ដោយប្តូរបាន ៧,៧៧៦ដុល្លារហុងកុង /ដុល្លារUS ។

In August 2006, the South Korean won depreciated slightly against the US dollar, trading at 960.95 KRW/USD compared to 954.45 KRW/USD a month earlier. During the same period, the Hong Kong dollar remained almost flat against its US counterpart, trading at 7.776 HKD/USD.

**KRW & HKD against USD**

August 05–August 06 (Monthly Average)




Source: Federal Reserve Bank of New York

នៅខែសីហា ២០០៦ ដុល្លារសិង្ហបុរី ឡើងថ្លៃបន្តិចទល់នឹង ដុល្លារUS ដោយប្តូរបាន ១,៥៧៥ដុល្លារសិង្ហបុរី/ដុល្លារUS រឺឡើងថ្លៃ ០,៥%ធៀបនឹងខែមុន។ ប្រាក់បាតថៃ ក៏ឡើងថ្លៃទល់នឹងដុល្លារUS ដែរ ដោយប្តូរបាន ៣៧,៥៩ បាត/ដុល្លារUS រឺ ឡើងថ្លៃប្រហែល ១% ធៀបនឹងខែកក្កដា ។

In August, the Singapore dollar gained slightly against the US dollar, trading at 1.575 SGD/USD, a half percent appreciation from the previous month. The Thai baht also strengthened against the US dollar exchanging at 37.59 THB/USD, an appreciation of about one percent from July.

**THB & SGD against USD**

August 05–August 06 (Monthly Average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែកក្កដា ថ្លៃអង្ករពិភពលោក នៅតែខ្ពស់ ដោយសារការផ្គត់ផ្គង់សំរាប់នាំចេញមិនគ្រប់គ្រាន់ និងតំរូវការកើនខ្លាំង ។ សន្ទស្សន៍ថ្លៃអន្តរជាតិ កើនដល់ ១៣០,១ពិន្ទុ ធៀបនឹង ១២៨,៧ពិន្ទុ នៅខែមិថុនា ។ នៅ US ថ្លៃនាំចេញកើនដល់ ៣៤៣,៧០ដុល្លារ/តោន ធៀបនឹង ៣៤១,៩០ដុល្លារ/តោន នៅខែមិថុនា ។ អង្ករ Thai 100%B លក់ថ្លៃ ២៩២,៩០ដុល្លារ/តោន ដោយកើនពី ២៨៨,៤០ដុល្លារ/តោន នៅខែមិថុនា ។

In July, world rice prices were firm due to a scarce exportable supply and more intense demand. The international price index (IPO) went up to 130.1, against 128.7 in June. In the United States, the export price increased to USD343.70 per tonne, against USD341.90 in June. Thai 100%B sold at USD292.90 per tonne, up from USD288.40 in June.

### International Price Index and Export Rice Prices
(USD/tonne FOB)




Sources: Osiriz/InfoArroz and InterRice

នៅខែសីហា ថ្លៃសណ្តែកសៀងធ្លាក់ចុះ រីឯ ថ្លៃពោត និងប្រេងឆា កើនឡើង ។ សណ្តែកសៀងលក់ថ្លៃ ២០៣,១០ដុល្លារ/តោន ធៀបនឹង ២១៦,៧០ដុល្លារ/តោន នៅខែកក្កដា ។ ពោតលក់ថ្លៃ ១០៣,៧០ដុល្លារ/តោន ធៀបនឹង ១០៣ដុល្លារ/តោន នៅខែកក្កដា ។ នៅខែកក្កដា ប្រេងឆា ឡើងថ្លៃដល់ ៤០៣,៦០ដុល្លារ/តោន ធៀបនឹង ៣៩៦,៤០ដុល្លារ/តោន នៅខែមិថុនា ។

In August, the price of soybeans declined, while the prices of maize and palm oil increased. Soybeans sold at USD203.10 per tonne, down from USD216.70 in July. Maize sold at USD103.70 per tonne, up from USD103 in July. In July, palm oil rose to USD403.60 per tonne, from USD396.40 in June.

### International Prices of Soybeans, Maize and Palm Oil (USD/tonne FOB)




Source: Food and Agriculture Organisation (FAO)

នៅខែសីហា ប្រេងឆៅនិងម៉ាស៊ូត ឡើងថ្លៃ រីឯប្រេងសាំង បែរជាធ្លាក់ថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៧០,៣៣ដុល្លារ/ធុង ធៀបនឹង ៦៩,២០ដុល្លារ/ធុង នៅខែកក្កដា ។ នៅ US Gulf Coast ថ្លៃម៉ាស៊ូត (មានលាយស្ពាន់ធ័មតិច លេខ២) កើន ១,២%ខ្ពស់ជាងខែមុន ដល់ ៥៩,៥១សេន/លីត្រ ។ សាំងធម្មតា (អុកតាន ៨៧) ធ្លាក់ថ្លៃអស់ ៦,០% មកត្រឹម ៥៥,៩សេន/លីត្រ ធៀបនឹង ៥៩,៦សេន/លីត្រ នៅខែកក្កដា ។

In August, the prices of crude oil and diesel increased, while the price of gasoline decreased. The OPEC spot price of crude oil was USD70.33 per barrel, against USD69.20 in July. The diesel (low sulfur No.2) price on the US Gulf Coast rose by 1.2 percent from the previous month to 59.51 US cents per litre. Regular gasoline (87 octane) prices on the US Gulf Coast decreased by 6.0 percent, to 55.9 US cents per litre compared to 59.6 US cents per litre in July.

### Prices of Crude Oil, Gasoline and Diesel




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច / Economic News

**ក្រុមហ៊ុន Huawei របស់ចិនសន្យាអនុវត្តគំរោង GMS-IS នៅកម្ពុជា:** ក្រុមហ៊ុនផ្គត់ផ្គង់សំភារៈទូរគមនាគមន៍នាំមុខគេរបស់ចិន ឈ្មោះ Huawei Technologies ថ្មីៗនេះបានចុះកិច្ចសន្យាពាណិជ្ជកម្ម ជាមួយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ដើម្បីបង្កើតគំរោងសេវាអ៊ិនធឺណិត ដែលនឹងផ្តល់ឱ្យកម្ពុជានូវមូលដ្ឋានផ្លាស់ប្តូរព័ត៌មានឌីជីថល ដើម្បីចែករំលែកជាមួយប្រទេសជិតខាង ។ ក្នុងគំរោងនេះ បណ្តាញទូរគមនាគមន៍ប្រើខ្សែកាបអុបទិក នឹងដាក់រាយពាសពេញប្រទេស ដើម្បីឱ្យមានសេវាអ៊ិនធឺណិតគុណភាពខ្ពស់រវាង កម្ពុជា ថៃ វៀតណាម ឡាវ ភូមា និង ចិន ។ លោក Duan Jinzhu ទីប្រឹក្សាស្ថានទូតចិន និយាយថា នេះជាផ្នែកមួយនៃផែនការច្រកធំសំរាប់បញ្ជូនព័ត៌មាននៅមហាអនុតំបន់មេគង្គ ដែលរដ្ឋាភិបាលចិននឹងជួយគាំទ្រខាងគោលនយោបាយ និងហិរញ្ញវត្ថុ ព្រមទាំងកំចីមានលក្ខខណ្ឌអនុគ្រោះតំលៃ ១៧,៥លានដុល្លារUS ។ លោកបន្ថែមថា ការសាងសង់ប្រព័ន្ធជាមូលដ្ឋាន ដូចជាគំរោងនេះជាដើម គឺជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការដ៏សំខាន់រវាងកម្ពុជា និងចិន ។ ចិនមានបំណងផ្តល់ជំនួយតាមគ្រប់លទ្ធភាពដល់កម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ នៅខណៈនេះដែរ ឯ.ឧ ជិន ប៊ុនស៊ាន រដ្ឋលេខាធិកាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បញ្ជាក់ថា គំរោងនេះសំខាន់ខ្លាំងណាស់ចំពោះតំបន់នេះ ដើម្បីបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចជាទូទៅ ហើយយើងសង្ឃឹមថា ច្រកធំសំរាប់បញ្ជូនព័ត៌មាននេះ នឹងធ្វើរួចរាល់ឆាប់ៗ ដើម្បីជាប្រយោជន៍ដល់ប្រជាជន និងប្រទេស GMS ។

**ផលិតផលកសិកម្មកម្ពុជាគ្មានគំរាមកំហែងអ្វីដល់វៀតណាមទេ :** នៅថ្ងៃទី១ ខែកញ្ញា ផលិតផលកសិកម្មប្រហែល ៤០មុខ របស់កម្ពុជាដែលនាំចូលទៅវៀតណាម នឹងត្រូវលុបពន្ធគយ ។ ការលុបពន្ធក៏អនុវត្តលើការនាំចូលបារីដែរ ប៉ុន្តែនឹងមានប្រើប្រព័ន្ធកូតាមួយ ដើម្បីដាក់កំរិតលើបរិមាណនាំចូលផលិតផលនេះ ។ ការនាំចូលផលិតផលកសិកម្មកម្ពុជា នឹងត្រូវធ្វើឡើងកាត់តាម ១៧ ច្រកព្រំដែន ។ លោក Nguyen Minh Nhi អតីតសមាជិកគណៈកម្មាធិការប្រជាជនខេត្ត An Giang មិនឃើញមានបញ្ហាចោទអ្វីទេក្នុងការអនុញ្ញាតឱ្យនាំចូលផលិតផលកម្ពុជា ដោយលោកលើកថា គ្មានផលិតផលកម្ពុជាណាមួយអាចប្រកួតប្រជែងនៅវៀតណាមបានឡើយ ។ លោក Nhi និយាយថា កាលពីមុនលោកធ្លាប់ចុះហត្ថលេខាជាច្រើនដងអនុញ្ញាតឱ្យនាំអង្ករកម្ពុជាចូលមកខេត្ត An Giang ដោយគ្មានពន្ធគយ ។ លោកបន្តថា កសិករកម្ពុជាអាចលក់អង្ករ និងផលិតផលផ្សេងទៀតរបស់ខ្លួននៅវៀតណាម បានថ្លៃខ្ពស់ជាងនៅកម្ពុជា ។ លោកគិតថា ការបារម្ភនាបច្ចុប្បន្នគឺ ផលិតផលថៃនឹងជ្រៀតចូលទីផ្សារវៀតណាម តាមរយៈប្រទេសកម្ពុជា ដើម្បីឆ្លៀតយកចំណេញពីការលុបពន្ធនេះ ។ នៅពេលផ្លែឈើ និងផលិតផលធ្វើពីស្ករបស់ថៃ ជ្រៀតចូលទីផ្សារវៀតណាម វាអាចជាការគំរាមកំហែងមួយយ៉ាងធំ ។ ឧទាហរណ៍ ផលិតផលធ្វើពីស្កររបស់ថៃ លក់ថោកជាងផលិតផលវៀតណាមជានិច្ច ។ ទិន្នផលអំពៅរបស់ថៃគឺ ៨០តោន/ហិកតា រីឯកសិករវៀតណាមទទួលបានតែ ៥០តោន/ហិកតា ប៉ុណ្ណោះ ។

***China's Huawei to undertake GMS-IS project for Cambodia:*** China's leading telecommunications equipment supplier, Huawei Technologies, recently signed a commercial contract with Telecommunications Cambodia to build an internet facility that will provide the country with a digital information exchange platform to be shared with its neighbours. Under the project, an optical fibre telecommunications network will be laid over the country to allow high-quality internet communication among Cambodia, Thailand, Vietnam, Laos, Myanmar and China. "This is a part of the Greater Mekong Sub-region Information Superhighway (GMS-IS) Plan, for which the Chinese government will extend policy and financial support as well as USD17.5 million worth of preferential loans", said Duan Jinzhu, counsellor at the Chinese Embassy. "Basic facility construction such as the GMS-IS project is part of the important cooperation between China and Cambodia. China is willing to give all possible aid to Cambodia to beef up its economic development", Duan added. Meanwhile, a secretary of state of Cambodia's Ministry of Posts and Telecommunications, Chin Bun Sean, emphasised that the project is very important for the region to step up its overall economic and social development. "We hope the information superhighway will be completed soon to contribute to the GMS countries and their people", he added. *(Cited from english.peoplet.com.cn 28 August 2006)*

***Cambodian agricultural products no threat in Vietnam:*** As of September 1, some 40 Cambodian agricultural products imported into Vietnam will have their duties removed. The removal of taxes also covers tobacco, but a quota scheme will be applied to limit imports of this product. The import of Cambodian agricultural products will be done via 17 border gates. Nguyen Minh Nhi, former An Giang Province Peoples' Committee member, did not see any challenge in allowing Cambodian products to be imported, saying that no Cambodian product can be competitive in Vietnam. "In the past, I have several times signed the decision to allow Cambodian rice to be imported to An Giang province with no duties", said Mr Nhi. He said that Cambodian farmers would be able to sell rice and other products at higher prices in Vietnam than in Cambodia. According to Mr Nhi, the concern now is that Thai products will penetrate Vietnam's market through Cambodia to take advantage of the removal of duties. Once Thai fruit and sugar products penetrate the domestic market, they would be a serious threat. Thai sugar products, for example, are always cheaper than Vietnamese products. While the Thai yield is 80 tonnes of sugar cane per hectare, Vietnamese farmers get only 50 tonnes. *(Cited from english.vietnamnet.vn 24 August 2006)*